# វេទិកាវៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤៩

## ក្រោមប្រធានបទ ការគ្រប់គ្រងធនធានមនុស្ស (ផ្តោតលើការជ្រើសរើសបុគ្គលិក និងការដោះស្រាយបញ្ហាបុគ្គលិក)

*ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០២៤*

*ម៉ោង ៨:៣០ ដល់ ៤:៣០ ល្ងាច*

*តាមរយៈការចូលរួមផ្ទាល់ នៅកាំបូឌីយ៉ាណា អូតែល*

## ១. សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) គឺជាអង្គការសមាជិកភាពឈានមុខ សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ដែលមានអង្គការមិនមែនរដ្ឋាភិបាលបរទេស និង ក្នុងស្រុក ចំនួន ១៨១ ជាសមាជិក ហើយមានអង្គការក្នុងស្រុកប្រមាណ ៣០០ ជាដៃគូ និងជាអ្នកទទួលផល។ បច្ចុប្បន្ន អង្គការ គ.ស.ក កំពុងអនុវត្តកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ចដំណាក់កាលទី៥ (GHP 2024-2028) ដែលជាគំនិតផ្តួចផ្តើមមួយ ក្នុងគោលបំណងជំរុញភាពជាដៃគូប្រកបដោយបរិយាបន្ន ដើម្បីអភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា។

ការគ្រប់គ្រងធនធានមនុស្សអោយប្រកបដោយប្រសិទ្ធភាព និងឱកាសនៃការទទួលបានការអភិវឌ្ឍន៍សមត្ថភាពដើម្បីឆ្លើយតបនឹងតម្រូវការការងារនាពេលបច្ចុប្បន្នគឺពិតជាតម្រូវការចាំបាច់សម្រាប់ស្ថាប័ន ក្នុងការថែរក្សាបុគ្គលិករបស់ខ្លួន ក៏ដូចជាសម្រាប់បុគ្គលិកផ្ទាល់ក្នុងការអភិវឌ្ឍន៍សមត្ថភាព។ ដោយយោងទៅតាមការស្នើសុំតាមរយៈការធ្វើការស្ទង់មតិរបស់អ្នកចូលរួមវេទិកាវៀនសូត្រផ្នែកធនធានមនុស្សនាចុងឆ្នាំ ២០២៣ កន្លងមកនេះ បានបង្ហាញថាអង្គការសមាជិករបស់គសក នៅតែត្រូវការបច្ចេកទេស និងយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ក្នុងការជ្រើសរើសបុគ្គលិកអោយសមស្របទៅតាមការងារ និងគន្លឹះក្នុងការដោះស្រាយបញ្ហានានាដែលអាចកើតមានរវាងបុគ្គលិកនៅក្នុងស្ថាប័ន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ដូច្នេះ ដើម្បីឱ្យអង្គការសង្គមស៊ីវិលអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រឹងសមត្ថភាពលើការគ្រប់គ្រងធនធានមនុស្សរបស់ខ្លួនអោយកាន់តែមានប្រសិទ្ធភាពនោះ អង្គការ គ.ស.ក នឹងរៀបចំវេទិកាវៀនសូត្រស្តីពី *"ការគ្រប់គ្រងធនធានមនុស្សដោយផ្តោតសំខាន់លើការជ្រើសរើសបុគ្គលិក និងការដោះស្រាយបញ្ហាបុគ្គលិក"* ដែលវេទិកានេះ នឹងប្រព្រឹត្តទៅឡើងនាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ។

## ២. គោលបំណងនៃវេទិកាវៀនសូត្រ

ក្នុងរយៈពេលមួយថ្ងៃនេះ អ្នកចូលរួមនឹងអាច៖

1. បង្កើនការយល់ដឹង ពីគន្លឹះសំខាន់ៗនៃការជ្រើសរើសបុគ្គលិក

2. សិក្សាស្វែងយល់ពីដំណោះស្រាយចំពោះបញ្ហាបុគ្គលិកដែលអាចកើតមាននៅក្នុងស្ថាប័ន
3. ពង្រីកទំនាក់ទំនងក្នុងចំណោមអ្នកកាន់តួនាទីផ្នែកគ្រប់គ្រងធនធានមនុស្ស។

## ៣. អ្នកចូលរួម និងការកំណត់តម្លៃនៃការចូលរួមក្នុងវេទិការៀនសូត្រ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស ដែលអញ្ជើញមកពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។

- **ការចូលរួមដោយផ្ទាល់**
  - **ផ្តល់ជូន ០២ កន្លែង សម្រាប់អង្គការសមាជិកនីមួយៗ។ បើមានអង្គការសមាជិករបស់អង្គការ គ.ស.ក មកលើស (ចាប់ពីអ្នកទី៣ទៅគឺ២៥USD/ម្នាក់)។**
  - **ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនមែនជាសមាជិកអង្គការ គ.ស.ក ចង់ចូលរួមដោយផ្ទាល់ត្រូវបង់ថ្លៃ ៥០ដុល្លារក្នុងម្នាក់ (ប្រសិនជានៅមានកន្លែង)។**

**សម្គាល់៖** ចំនួនមានកំណត់ សូមចុះឈ្មោះជាមុនតាមរយៈតំណរចុះឈ្មោះដែលបានផ្តល់ជូន។
សូមធ្វើការចុចលើតំណភ្ជាប់ខាងក្រោមដើម្បីចុះឈ្មោះចូលរួម៖
https://www.ccc-cambodia.org/kh/resources/event-calendar/2024-05-02/hr-learning-forum-9

| ៤. របៀបវារៈ | | |
|---|---|---|
| **ម៉ោង** | **មាតិកា** | **អ្នកសម្របសម្រួល** |
| ០៧:៤០ -០៨:១៥ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គ.ស.ក |
| ០៨:១៥-០៨:៣០ | - ការណែនាំពី បទបញ្ហាផ្ទៃក្នុងសម្រាប់វេទិការៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិការៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br>អង្គការ គ.ស.ក |
| ០៨:៣០-៨:៤០ | កិច្ចស្វាគមន៍ដោយតំណាងអង្គការ គ.ស.ក | **លោក អ៊ុំ សារអន**<br>ប្រធានផ្នែកប្រតិបត្តិការនៃអង្គការគ.ស.ក |
| ៨:៤០ -៨:៤៥ | ការថតរូបជុំគ្នា | |
| ៨:៤៥ -១០:០០ | **<u>បទបង្ហាញស្តីពី៖</u>**<br>វិធីសាស្ត្រក្នុងការជ្រើសរើសបុគ្គលិក | **លោក ភាព មនោ**<br>សមាជិកក្រុមការងារធនធានមនុស្សនៃអង្គការគ.ស.ក និងជាប្រធានគ្រប់គ្រងថ្នាក់តំបន់នៃ |

| | | |
|---|---|---|
| | | ស្ថាប័ន Clinton Health Access Initiative |
| ១០:០០ -១០:១៥ | សម្រាកអាហារសម្រន់ | |
| ១០:១៥ -១២:០០ | **<u>បន្តបទបង្ហាញស្តីពីះ</u>**<br>វិធីសាស្រ្តក្នុងការជ្រើសរើសបុគ្គលិក<br><br>(សំណួរ និងចម្លើយ) | **លោក ភាព មនោ**<br>សមាជិកក្រុមការងារធនធានមនុស្សនៃអង្គការគ.ស.ក និង ជាប្រធានគ្រប់គ្រងថ្នាក់តំបន់នៃស្ថាប័ន Clinton Health Access Initiative |
| ១២:០០-១:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |
| ១:៣០-៣:០០ | **<u>បទបង្ហាញស្តីពីះ</u>**<br>គន្លឹះសំខាន់ៗក្នុងការដោះស្រាយបញ្ហាបុគ្គលិក | **លោក សេង សារុធ**<br>សមាជិកក្រុមការងារធនធានមនុស្សនៃអង្គការគ.ស.ក និង ជាប្រធានគ្រប់គ្រង V Charted Accountants |
| ៣:០០-៣:១៥ | សម្រាកអាហារសម្រន់ | |
| ៣:១៥-៤:២០ | បន្តប្រធានបទខាងលើ<br>(សំណួរនិងចម្លើយ) | **លោក សេង សារុធ**<br>សមាជិកក្រុមការងារធនធានមនុស្សនៃអង្គការគ.ស.ក និង ជាប្រធានគ្រប់គ្រង V Charted Accountants |
| ៤:២០-៤:៣០ | បិទកម្មវិធី | |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ អង្គការ គសក នឹងយករូបថតនៃវេទិការៀនសូត្រនេះសម្រាប់ការប្រើប្រាស់ផ្លូវការផ្សេងៗ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់* *raingsey.roeung@ccc-cambodia.org*